Khmer Story Lovers

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៧៨ ទីស្នាក់លេខ ២៨៨ បឹងកេងកង សង្កាត់លេខ ៨ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នករៀបរៀង : អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ២៦

បុរសអាវខៀវមើលញញឹមមុខនៀវនឹងឆ្ងល់ផង ណ្ណាំងសួរក្នុងចិត្តថា ម៉េចគាត់ដឹង ?

ស៊ីឈីនបន្ត :

– យើងមិនដែលមានសុលមេមាស់ ជាមួយលោកគ្រូលូស៊ីម៉ាទេ ។ បើគាត់ចាត់មនុស្សតាមដានយើងមែន... ហ៊ឹះ ! ប្រាប់ឯងតាមត្រង់ចុះ ! លូស៊ីម៉ាស្គាល់យើងស្រាប់ គាត់មិនបញ្ជូនមនុស្សល្ងីល្ងើថោកថោស អញ់ដូចឯងទេ !

ពាក្យនេះមានន័យថា បុរសអាវខៀវមិនមែនជាជាងក្តីប្រពន្ធគាត់ទេ ! បុរសនោះស្រឡាំងមុខទៅ ប៉ុន្តែគ្មានចំណាំមើលឃើញទេ ។ ស៊ីឈីនពោលចប់លើកដៃចង្អុលបុរសអាវខៀវជាថ្មី ៖ បន្តវាចា :

– ប្តីប្រពន្ធយើងចិត្តល្អ ហើយស្មោះត្រង់ណាស់ ពុំការអ្វីមិនចេះលាក់លៀមឡើយ ។ បើឯងចង់ដឹង ចាំយើងប្រាប់ណា ! អម្បាញ់មិញយើងចេញពីកាស្រមសាំងឈីង ក្រោយពេលទៅលេងទីនលោកឥសីតានស៊ី ។ ឯងទៅជួបគ្រូសុំសួរមើលតើស៊ីឈីននិងវុឌយុធ្លាប់ហាក់រៀនគុនវិជ្ជានៅកាស្រមនោះមែនឬទេ ? លោកឥសីតានស៊ីត្រូវជាបងរួមគ្រូរបស់យើងដែរទៀតផង ។ ឥឡូវនេះយើងធ្វើដំណើរទៅកាន់ភ្នំទឹកកក ជួបលោកតាយក្រុម

ម៉ាយដីតាយណា ! មិត្តបងប្អូនក្រង់ណាទៀតទេ ? បើអស់ការសង្ស័យ សូមអញ្ជើញទៅចុះ ។

បុរសកាវទៀតកាចកម្រើកបានហើយ ព្រោះអម្បាញ់មិញស៊ុកប៉ាន់ទះស្មាគេ ស្រាយជីពចរមោះ
ងន ។ គេស្ងើចសរសើរទឹកចិត្តសប្បុរសនៃប្តីប្រពន្ធស៊ុយឈិនណាស់. ហើកវ៉ៃគោរពលាភ្លាម:

- សូមអរគុណលោកម្ចាស់ដែលបានបើកផ្លូវជីវិតខ្ញុំបាទ ។ សូមលាហើយបាទ!

ពោលចប់គេដូនរើសកាបិតដាក់ចន្លុះខ្លួន បែរមកលំពែនកាយដាក់អ្នកស្រីនុងយូ :

- សូមលោកស្រីមេត្តាអភ័យទោស ។

អ្នកស្រីស៊ុំសំដែងការតិត្តកប់វិញយ៉ាងសុភាព បុរសកាវទៀតងាកខ្លួនដើរចេញទៅ, ស៊ុយឈិនសួរ
ទៀត :

- នៃមិត្ត, កេនាយក្រុមឃើញឬទេ ?

បុរសភ្ញាក់ព្រើតងាកក្រោយខ្លាច :

- លោក ... លោកជ្រាបសព្វគ្រប់ហើយឬ ?

ស៊ុយឈិនងក់ផ្ងើមក :

- យើងមិនដឹងដែរ ។ មើលទៅ, គ្មានដំណឹងបន្តិចណាសោះឬ ?

បុរសនោះគ្រវីក្បាល:

- បាទទេ, គ្មានដំណឹងអ្វីទាំងអស់ ។

- ហ៊ឺ ! ប្តីប្រពន្ធយើងកំពុងតាមរកគេដែរ ។

អ្នកទាំងបីឈរមើលមុខគ្នាដោយស្ងៀមស្ងាត់ មួយសន្ទុះទើបបុរសកាវទៀតចាកចេញទៅ ។
មួយស្របក់ទើបនុងយូសួរស្វាមី:

- បងឈិន, គេជាបក្សពួកឈានល្អឬ ?

ស៊ុយជានព្រះឈ្មោះក្រុមលោះឆល្អចិត្តពោះគំបង, ស៊ុយបើងឆ្លើយថា :

- នៅពេលគេងាកខ្លួនដើរចេញទៅ បងឃើញហាក់ដូចជាយកាវគេមានបាក់រូបឬបាតណាញៀន ។
ឥឡូវសួរទៅគេឆ្លើយយ៉ាងនេះមែន ហ៊ឺ ! ...គេតាមយើងយើងប្បែ....កូនយើងសោះអ្ហ៎ ! បើដឹងដូច្នេះយើង
មិនបាច់ធ្វើបាបគេទេ, អាណិតណាស់ !...

អ្នកស្រីមានទឹកភ្នែករលីងរលោង:

-ហ៊ឺ ! ក្រុមគេស្មោះត្រង់នឹងគូនយ៉េណាស់ហ្ន៎ !

-មែន ! ប៉ុយវ៉ាំងដាំងចាប់គូនយ៉េនទៅ ព្រោះជាក្រុមឈានល្អ ចាក់នឹងគ្នាតាមកេគ្រប់ច្រកល្ហក ហើយ ! គេមានគ្នាច្រើន, ត្រៀមទៅវៃគេនឹងគ្មានបានដំណឹងអ្វីបន្តិច···ហ៊ឺ !...

អ្នកស្រីនុនយូកាន់តែខ្លាចផ្សា :

- ម៉េច . . ម៉េចបងដឹងគេគ្មានទុំឡូលដំណឹងអ្វី ?

ស៊ីណង់ទាញដៃភរិយាទៅអង្គុយក្រោមដើមឈើធំពោលលួងលោម :

- អូនគិតមើល ; បើពួកគេបានដំណឹងអ្វីពីគូនយ៉េ គេមិនបាច់ចាត់សេនាតាមដានអ្នកគុនឌិយម គ្រប់ទិសដែលខ្លួនដូច្នេះឡើយ ។ អម្បាញ់មិញសិស្សប្រុសម៉ាតាមយើងប្រកិតប្រាប់ថាគេគ្មានបំណង អ្វីក្រៅពីចង់បានដំណឹងនាយក្រុមរបស់គេទេ ។

ប្ដីប្រពន្ធស៊ីណង់អង្គុយក្រោមដើមឈើជិតកន្លែងស៊ីផាំងពួន ឃ្លាតគ្នាប្រហែលពីរព្យាមប៉ុណ្ណោះ ទើបស៊ីផាំងស្ដាប់ឮទាំងអស់ ទោះស៊ីណង់និយាយតិចៗក្ដី ។

ប្ដីប្រពន្ធស៊ីណង់មានយុទ្ធសិល្បៈខ្ពង់ខ្ពស់ប៉ុណ្ណឹង គួរណាស់តែដឹងថា មានស៊ីផាំងកំពុង ដែរ តែដោយហេតុបុរសការទៀបខ្លួយជាទីមាលល ទើបគាត់យកចិត្តទុកដាក់តែលើមនុស្ស ម្នាក់កុំឲ្យស៊ីផាំងតាមរហូតមក ។ ជាពិសេសមាណពបានកប៉ាំងខាងក្រៅប្រុះអ្នកប្រញាប់ស្ទួ ទើបប្ដីប្រពន្ធស៊ីណង់ស្មានថាអស់មនុស្សនៅជិតហើយ ។

ស៊ីផាំងពួនក្នុងគុម្ពស្មៅស្ដាប់ប្ដីប្រពន្ធស៊ីណង់និយាយរឿងប៉ុយវ៉ាំងដាំងចាប់ «គូនយ៉េ» គាត់ពោក ដូចនិយាយរឿងនាយពិតៗ តែ«គូនយ៉េ»ជាអ្នកណា? នាយឆ្លើយមិនរួចសោះគ្រាន់តែដឹងថាខ្លួនមិនមែន «គូនយ៉េ»នោះទេ ។

តាំងពីដើមមក, មាណពសង្ស័យពីប្រវត្តិខ្លួនណាស់ ហើយចង់ដឹងណាស់រឿងនានា ។ ពេល នេះបើស្ទុះចេញមកដូចជាមិនសម ម្ល៉ោះហើយនាយសម្ងំរង់ចាំស្ដាប់ទៀតក្រែងបានដឹងរឿងផ្ទាល់ខ្លួន ។

## ខណ្ឌទី ២៥

## ដៃជាវដើមហេតុនៃគ្រោះថ្នាក់

ពេលនេះស្ងាត់ជ្រៀប ! ក្រៅពីចង្រិតយំច្រៀបៗ ក្នុងគុម្ពស្មៅ គេឥតឮសូរអ្វីទៀតឡើយ ។

Khmer Story Lovers



ជំនោរពក្រើបក្រោកសៀកបោះបោសអន្ទែលការម្មណ៍ ប្តីប្រពន្ធស៊ុយីន ដែលអង្គុយស្ងៀមមួយស្របក់ហើយៗ ស៊ុំផងនាទីតែតែទំសម្លុំឥតហាក់ដកដង្ហើមខ្លាំងឡើយ ។

មួយរយៈពេលក្រោយមក ទើបនាយតុក្កស្រីដកដង្ហើមយូរ រួចយំសោកខ្សឹកខ្សួលគួរអាណិត ។ ស៊ុំឈីកិលួនលោម :

-អូនយូ, យើងរើវង្វេងព្រេងក្នុងពិតគុនតាំងពីដើមមក មិនដែលប្រព្រឹត្តអំពើទុច្ចរិត ឬសាង បាបកម្មអ្វីសោះឡើយ ។ ចូនប្រាំឆ្នាំក្រោយនេះ យើងរឹតតែសន្សំកុសលផលបុណ្យផ្តល់ឲ្យកូន យើទៀត ។ បើវាសនាយើងត្រូវគ្មានកូនតពូជពង្សត្រកូលទេ គួរបណ្តោយតាមព្រហ្មលិខិតចុះ ។ ម៉្យាងទៀតកូនអកតញ្ញូបៀបំ « កូនយើ » យើងនេះ, គ្មានកូនប្រសើរជាង ។

អ្នកស្រីបង្ហឹបពាក់តាំងអាក់អួល :

- កូនយើស្លាប់ពីលទូបតាំងពីតូចមែន, តែ... គឺកូនសំណប់តែមួយរបស់យើង.. ដើមហេតុមកពី កូនបានស្លាប់យ៉ាងអាណោចអាធ័ម បាងជាយើងស្រឡាញ់ថ្នាក់ថ្នមទំយើកូនយើងាលតែខូចរសៈ ៗ នេះ ខ្ញុំមិនតូចចិត្តទេ, តែកាលយើងជួបវាក្នុងខ្លួមកញ្ចាស់ ដូចជាមិនវិលខូចហួចគេជាទេ ។ បើកុំ តែខ្ញុំជ្រួលដៃពាក់ក្រូវវា ... ប្រហែល ...

អ្នកស្រីក្តុកក្តួលអួលបំពង់កនិយាយលែងចេញ ។ ស៊ុំឈើងខូម្ចាន :

- បងប្រាប់ហើយថា កុំគិតច្រើនពេក, ថ្វីដោះទោះយើងជួយវាចេញផុតមកក៏ប្រហែល ជាយកន់ជានដេញតាមដណ្តើមទៅវិញបានដែរ ។ ចរ៉ៃគណាស់ អូនអើយ ! ក្រុមក្អែកកក ទៅណា បាត់អស់គ្មានលេចពុធំណាំងអ្វីក្នុងពិតគុនសោះ ។ យើងស្រុតធំណើរទៅកាន់ក្អែកកក ឬ ? ទោះបីយ៉ាងណាត្រូវស៊ើបដំណឹងឲ្យច្បាស់លាស់ដែរ,មែនទេ ?

អ្នកស្រីសួរបែបល្បើយ :

-យើងមិនរកមិត្តភក្តិខ្លះជួយទេឬ ? ទៅជំរំខ្ញាដូចេះមិនងាយរំដោះកូនយើចេញផុតទេ ។

ស៊ុំឈីងដកដង្ហើមធំ :

- ជួយមនុស្សមួយតាំងមូលមិនមែនជាការងាយទេ, តោនស្កាត់វាយដណ្តើមកណ្តាលផ្លូវទើប មានសង្ឃឹម ។ បើគេនាំកូនយើងដល់ក្អែកកកហើយ រៀងនេះប្រៀបដូចកណ្តុរនៅក្នុងមាត់ ឆ្មាអីចឹង ?

– ខ្ញុំយល់ថា រឿងហេតុអស់នេះមិនមែនធ្លាក់លើកូនយើងទាំងអស់ទេ ។ បងមើលបុះគុន ជាវគ្គទឹកកកដែលកូនយើងសំដែងក្នុងខ្លួនមកច្បាស់ពិតជាខ្លាំងណាស់ , ប្រហែលក្រុមគ្រូទឹកកកមិនយកចិត្តទុកដាក់បង្រៀនកូនយើងឲ្យហ្មត់ចត់ណា ។ បានជាកូនយើងប្រែក្លាយជាការបរាជ័យរឿងធ្ងន់ធ្ងរ . . . មិនដឹងកូនខ្ញុំវេទនាយ៉ាងណាទេ ។

– រឿងនេះមកពីបងយល់ខុស , សូមអូនអត់ទោសឲ្យបងផង ។ ថ្ងៃនោះបងបានសម្រេចចិត្តបញ្ជូនកូនប្រុសទៅហាត់រៀនយុទ្ធសិល្បៈទៅក្នុងទឹកកក អូនមិនដឹងសោះទេ , តែបងយល់ចិត្តអូនណាស់ថា អូនមិនយល់ស្របទេ ។ ម្យ៉ាងទៀតបងមិនទាន់ស្មានថា នាគភ្លើងហុងលីដែលជាអ្នកគ្រូហាត់ល្បីល្បាញហើយជាមិត្តស្និទ្ធស្នាលរបស់យើង បែរជាហ៊ានប្រព្រឹត្តដូច្នេះជាមួយកូនយើងសោះ ។

– ល្អើយ រឿងនេះមិនត្រូវបន្ទោសបងទេ ។ បងបញ្ជូនកូនទៅហាត់រៀនគុនវ៉ៅថ្លាងក្នុងទឹកកកពីបងស្រឡាញ់ខ្ញុំហើយ , ទោះបងមិននិយាយក៏ខ្ញុំដឹងដែរ ។ ព្រោះរឿងបងសឹកត្រូវតែគួរ យើងត្រូវធ្លាក់លើខ្លួនខ្ញុំទាំងស្រុង ទាល់តែបញ្ជូនកូនទៅរៀនគុនជាវគ្គពិនាពុម្ពកម្មង្ឃាំងធ្លាយបន្ទិច កូនទើបបានសង្ស័យប្រហារបត្រូវបាន ។ សត្រូវនោះស្គាល់ការពារយុទ្ធសិល្ប៍ យើងច្បាស់ណាស់ណាស់ ។ ពេលនេះ ហ៊ុ ! ....

ស៊ីផានលឺបណ្ដាប់កិច្ចសន្ទនារវាងប្ដីប្រពន្ធស៊ុយឆាំងដោយការងឿងឆ្ងល់ពន់ពេកណាស់ នាយសម្រេចចិត្តថា :

– លោកស្រីស៊ុយព្រួយចិត្តតែរឿងកូនមួយនេះហ៎ , គាត់នឹករឭកកូនគ្រប់ពេលវេលា ។ បើក្រុមគ្រូទឹកកកចាប់កូនគាត់យកទៅកន្លែងគេមែន , យើងត្រូវទៅក្នុងទឹកកកជាមួយគាត់ជួយដោះកូនគាត់ទាល់តែរួច ។ អម្បាញ់មិញគាត់ចង់កេត្តិគាត់ជួយដែរតើ ។

ពេលដែលមាណពសញ្ជ័យគិតនោះស្រាប់តែឮជើងសេះគុបៗពីចម្ងាយមក ទំនងជាមានសេះច្រើន ៗ ប្តីប្រពន្ធស៊ុយឆាំងផ្អាកការសន្ទនាសម្ងំស្ងៀមដើម្បីស្តាប់ ។ មិនយូរប៉ុន្មានឮសម្លេងស្រែកថា :

– ត្រង់នេះហើយ , ត្រង់នេះហើយ !

សម្លេងមួយទៀតស្រែកសួរ :

– អីប្អូនប្រុស , ប្អូនស្រី , បងមានការនិយាយបន្តិច ។

នេះជាសម្លេងឥសីឈុនស៊ី ។ ស៊ីឈីនទិនវុនយូម៉ីមាលោតចេញមកចាំងធៀងឆ្វេង ។ ស៊ីនឈីនស្រែកតបវិញ :

លោកបងឈុនស៊ីមានរឿងហេតុអីនៅកាស្រមប្អូ ?

ឥសីធានស៊ី, ឈុនស៊ីនិងបងប្អូនជាងដប់នាក់ជិះសេះគ្រហេបគ្រហបតម្រង់មក, មានចាំងឥសីពីររូបទបមនុស្សម្នាក់មួយផង តែមើលមុខមិនស្គាល់ព្រោះមេឃងងឹត ។

ឥសីឈុនស៊ីស្រែកចាំងអន្ទះអន្ទែង :

- ប្អូនស៊ី...កាលនៅក្នុងកស្រមប្អូនចាំងពីដណ្ដើមផ្កាស្អាងមិនបានទេ, ហេតុអីក្រោយមកប្អូនប្រើកលល្បិចដណ្ដើមយកទាល់តែបាន ? មិនតែប៉ុណ្ណោះប្អូនសម្លាប់ឥសីចាវស៊ីនិងថុងស៊ីទៀត ! ធ្វើបែបនេះមិនល្អទេ !

ស៊ីឈីនទិនវុនយូប្រហោងពោះធុំ ។ ស៊ីឈីនភ័យចំពោះបងរួមគ្រូពេកមិនបានរែកញែក ក៏សួរភ្លាម :

- លោកបងចាវស៊ីនិងថុងស៊ីត្រូវគេសម្លាប់ ? រឿងនេះបណ្ដាលមកពីអ្វី ? ឥឡូវយ៉ាងម៉េចហើយ ?

ឥសីឈុនស៊ី បញ្ចេញខ្យល់តាមច្រមុះហ៊ឺ ! ឆ្លើយសោះកក្រោះថា :

- មិនដឹងពួកឯងបានទាក់ទងនឹងជនថោកទាបប្រភេទណា បានជាហ៊ានប្រើពិសពុលដែលអ្នកគុណធិយមសុចរិតខ្ពើមរអើម ! ប្អូនចាំងពីមិនទាន់ស្លាប់ទេ នៅសល់ដង្ហើមផ្ដក ៗ ដែរ ។

- សូមលោកបងកុំអាលប្រទេញ្ញាតខ្លាំងពេក, ខ្ញុំសុំមើលបន្តិចសិន ។

ស៊ីឈីនបោះជំហានទៅមុខដើម្បីពិនិត្យឥសីចាវស៊ីនិងថុងស៊ី, ស្រាប់តែឮខ្លាក ៗ ... ឥសីប្អូនប្រាំរូបហូតដាវឃាំងពីមុខស្រុះគ្នា ។ ឥសីធានស៊ីដកដង្ហើមធំ:

- ចៀសចេញឲ្យអស់ ! ប្អូនស៊ីមិនមែនមនុស្សពុនហ្នឹងទេ !

ឥសីដែលកាន់ដាវធ្វើហ៊ឺះ ! នៅបុងច្រមុះ ហើយថយក្រោយតាមបញ្ជា ។ ស៊ីឈីនគួសភ្លើងបញ្ចាំងមើលមុខឥសីចាវស៊ីនិងថុងស៊ីឡើងពណ៌ខ្មៅខៃ ប្រាកដជាត្រូវជាតិពិសមែន ។ គាត់លូកដៃស្ទាបស្ទង់ដង្ហើមក៏ខ្សាយទឹកថា:

- មើលទៅរស់មិនបានយូរទៀតទេ ។

ត្បិតយុទ្ធសិល្បៈក្រុមអាស្រមសាំងឈើង មានមូលដ្ឋានស្អុកស្គម្ភណាស់ ។ ឥសីបាវស៊ុំមិន ថុងស៊ុ សុទ្ធសឹងជាសិស្សចំណោមផង ទើបមិនស្ទាប់ទាន់ហាន់ដូចក្រុមត្បូងដែក ។ កាលដែល ស៊ុយជានខេះទៅ ទោះគាត់ដួលផ្កាប់មុខសន្លប់ភ្លាម ។

ស៊ុយឈីងគ្មានសន្សឹមបណ្ដូយបង្វិលត្រូវបាន ក៏ស្រែកសួរតវ៉ា :

– អូនយូ, ជួយមើលមើល ? នេះជាស្នាដៃក្រុមបក្សណា ?

ជាមួយនឹងពាក្យនោះគាត់ដើរមុខទៀតឃើញឥសីចាំងអស់កាន់ដាវឈរព័ទ្ធប្ដីប្រពន្ធគាត់ជុំវិញ ។ អ្នកស្រីធ្វើហាក់មិនឃើញហេតុការណ៍នេះទេ , គាត់ខ្វល់តែពីស្វាមី ចូលមកពិនិត្យទឹកមុខអ្នករងគ្រោះទាំងពីរ អ្នកស្រីពុទ្ធិនស្ទាបតាមគ្រប់ដង្ហើមដ៏ខ្សោយនៃឥសីរងគ្រោះ គាត់បង្វិលមុខភ្លាម ទើបងើយក្រោយមួយជំហាន សញ្ជឹងគិតមួយស្របក់ ។ បន្ទាប់មកគាត់បញ្ចេញយោបល់ :

– នៅក្នុងពិភពគុនសព្វថ្ងៃនេះ ដូចជាមិនទាន់ប្រទះពិសពុលបែបនេះទេ ។ សុំសួរលោកបងឡុងស៊ុំមើល , តើលោកបងចាំងពីរនេះត្រូវពិសធ្វើទុក្ខបែបណា ? គាត់ប្រឹងលេបថ្នាំគុណក្រៅវរុនសង្កត់កំពិសរបស់សត្រូវ ? ហេតុម្ដេចមិនឃើញស្លាកស្នាមរបួសសោះ ?

ឡុងស៊ុំគំហកខ្លាំងៗ :

– យើងដឹងម្ដេចកើត ? ត្រូវសួរឯងវិញទេតើ ! ឆាងហានកលល្បិចទុច្ចរិត បំពុលមនុស្សល្អទេ ! ប្រហែលរមៀតញ៉ាញ់ម៉ាញឯងដណ្ដើមផ្កាកស្ពាន់មិនបាន លបលួចដាក់ថ្នាំពុលក្នុងស្រាហើយ ។ បើមិនដូច្នេះទេ, ម្ដេចក៏ពួកឯងទៀតមិនត្រូវពិស ? ត្រូវតែប្អូនបាវស៊ុំដែលមានផ្កាកស្ពាន់ក្នុងដៃ ? ម្យ៉ាងទៀត ... ហ៊ឹះ ! ... ផ្កាកស្ពាន់នៅក្នុងដងការក៏ត្រូវឯងលួចយកបាត់ទៀត !

វ៉ុនយូចឹងឡើងមុខសស្លេក ស្លឹកស្លាំង ។ គាត់ធ្លាប់មានចរិយាទន់ភ្លន់ស្លូតបូតតាំងពីដើមមក, របាគារពគួរសមចំពោះប្រុងចាំងអស់ មិនដែលខុសរក្សាស្រ័យណាម្នាក់ណាឡើយ ហេតុនេះនៅពេលគួរកាក់ក្ដួលក្ដុកចុកណែនទ្រូងដូច្នេះ ដូងនេត្រាចាំងគូកំលើងលោងមួយរំពេច តែគាត់ខំទប់អារម្មណ៍សង្កត់ចិត្តមិនឲ្យតំណក់ទឹកភ្នែកហូរហៀរចេញមកបានឡើយ ។

ស៊ុយឈីងយល់ថា រឿងនេះប្រាកដជាបណ្ដាលមកពីការគំនុំចងកំហឹងម៉្យាងមិនខាន ។ ត្បិតកាលនៅអាស្រមសាំងឈើង ប្ដីប្រពន្ធគាត់បានប៉ងដណ្ដើមផ្កាកស្ពាន់ដែរ តែមិនបានសម្រេច ហើយពេលនេះបាវស៊ុំត្រូវពិសពុលបាត់ផ្កាកស្ពាន់ពីខ្លួន គឺជាកត្តាមួយជម្រុញពួកគេឲ្យសង្ស័យប្ដីប្រពន្ធគាត់

តាំងស្រុង ។ គាត់ភ្ជាប់ដៃភរិយាផ្អួសការលួងលោម តែខ្លួនឯងក៏សោកសៅខ្វល់ខ្វាយណាស់ដែរ រកគិតអ្វីពុំឃើញឡើយ ។

អ្នកស្រីស៊ីស្រេងីបានតែពាក្យខ្ញុំ ... ខ្ញុំ ... ក៏ទ្រហោយំអើង ដោយទ្រាំទ្រអត់ធ្មត់តទៅទៀតលែងកើត ។ ពិតហើយថា វុនឃូជាវីរនារីកំពូលមានប្រកបដោយយុទ្ធសិល្បៈគុនដាវយ៉ាងជំនាញ ល្បីល្បាញសុសសាយពេញពិភពគុន តែនៅចំពោះមុខការបួលបង្កាប់ដ៏អយុត្តិធម៌ និងជាក់ស្តែង ពីសំណាក់បងប្អូនគ្រួព្រោះ តើមនឲ្យគូនចិត្តរំជើបរំជួលជ្រួយប្រេបប់ ដែលជាធម្មជាតិរបស់ស្ត្រីកម្រើកឡើងឯណាបាន ?

ឈុងស៊ីស្រែកទៀតថា :

–ពោះខំស្រែកយំយ៉ាងណា ក៏ចិត្តក្រុករបស់នាងមិនអាចព្រោះប្អូនប្រុសគ្រួចាំងពីឲ្យរស់រកមានជីវិតរស់រៀងវិញបានដែរ ! ហ៊ុះ កណ្តុរស្លាប់ ឆ្មាធ្វើជាបរិសោក ...

–រំលមិនចាំនចប់ស្រួលបួលផង ស្រាប់តែមានសម្លេងមួយជ័ន្ទាំងនៅខាងក្រោយខ្នងគាត់:

– មើលអស់លោកមិនរកខុសត្រូវសិន ប្រញាប់តែចោទប្រកាន់គេផ្តេសផ្តាសម៉េចង ?

សូរសព្ទខ្ទរខ្ទារលាន់គងរំពង បញ្ជាក់ឲ្យដឹងថា ម្ចាស់សម្លេងមានកម្លាំងកាយស្តុកស្តម្ភណាស់ ។ អ្នកកល់គ្នាភ្ញាក់ព្រើត ងាកក្រោយជាបន្ទាន់ ។ ក្រោមរស្មីភ្លើងស្រអាប់ៗ នៃដួងចន្ទ្រា គេឃើញយុវបុរសម្នាក់ប្រកបដោយសំលៀកបំពាក់យ៉ាងរយីករយាក ។ ស៊ុំពេជ្រនិងវុនឃូគ្រាន់តែប្រទះមាណពភ្លាមក៏ឱកអរកើត ។ អ្នកស្រីស៊ីស្រែកឮ ! ហើយឧទាន:

– ឯង...ឯង...

តែដោយញាប់មានការពិរោធខ្ញាល់ខ្លាំង ក៏ចប់មាត់ទាន់ មិនភ្លាត់ហៅ "កូនយី" ។ យុវបុរស គឺស៊ុំផានចាំងសាប់ចាំងឈាម ។ នាយសម្ពុងគិតម្តេចស្តាប់ពួកឥស្សីហោចប្រកាន់ថ្លៃប្រពន្ធស៊ីឈឹងឃាតបាតការពិតក៏ឱកថា មើលចេញទៅច្បាស់ជាត្រូវប្រយុទ្ធនឹងពួកឥស្សីសាំងឈឹងមិនខាន ហើយពេលនោះដៃនាយមានពិសស្រាប់មុខជាសម្លាប់មនុស្សទៀតហើយ ។ អំពើនេះជួយមិនបំណងមាណពចាំងស្រុង តែលុះស្តាប់ឃ្លូវទៅសំដីឈុងស៊ីកាន់តែខ្ទះការគួរសមឡើង ធ្វើឲ្យអ្នកស្រីស៊ីយំយ៉ាងអាណោចអាធ័ម នាយអត់ទ្រាំលែងបាន ក៏ស្ទុះចេញមកភ្លាម ។

ឈុងស៊ីតិហាក :

Khmer Story Lovers



- ឯងជាអ្នកណា ? ហេតុអ្វីហ៊ានថាយើងលេងផ្តេសផ្តាស ?

ស៊ីផានតប :

- លោកម្ចាស់ក្មួយស៊ីនឹងកិរិយាតុចុះប៉ះពាល់ផ្កាកស្តាន់នោះ តែរបស់លោកបែរជាបង្អាប់គាត់ ជាបានល្អកលាន់ក្នុងរឿងនេះ បែនគិតនិយាយផ្តេសផ្តាសទេឬ ?

ឈុងស៊ីកាន់ជាវស្ទុះទៅមុខមួយជំហាន :

- ឯងជាកូនក្មេងចេះដឹងអី ទើបហ៊ានពោលពាក្យមិនសមរម្យនៅទីនេះ ?

- ម៉េចលោកថាខ្ញុំមិនចេះដឹងអី ?

នាយចង់និយាយប្រាប់ថា ផ្កាកស្តាន់នៅលើដៃខ្ញុំនៅជាវ តែមកនឹកថាៈបើប្រាប់ឲ្យដឹង ពួកគេមិនជំណឿមយកវិញជាប្រាកដ ហើយពេលនោះនាកប្រយុទ្ធគាប់សម្លាប់គ្នាច្បាស់ជាផ្ទុះឡើងពុំខាន ហេតុនេះ ទើបនាយណកមិនហ៊ាននិយាយ ។

ឈុងស៊ីប៉ាន់ថា ប្រហែលមានភាពដឹងអាថ៌កំបាំង ក៏សួរភ្លាម :

- បើដូច្នេះអ្នកណាយកទៅ ?

ស៊ីផានឆ្លើយធ្វើហី :

- ខ្ញុំគ្រាន់តែសុំប្រាប់យ៉ាងខ្លីថា មិនមែនលោកប្រុសលោកស្រីទេ ! របស់លោកបានប្រព្រឹត្តមិនគប្បីចំពោះគាត់ ពិសេសប្រមាថទាល់តែលោកប្រើស៊ីប្រែកាយ ធ្វើដូច្នេះមិនសមសោះ ត្រូវនាំសុំទោសគាត់ភ្លាមឡើង !

វុនយូឃើញកូនប្រុសដែលគាត់តែងនឹករឭកចាំងយប់ចាំងថ្ងៃបានប្រកបនឹងសេចក្តីសុខ បំភ្លេចដូច្នោះ គាត់ត្រេកអរពេកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។ ពេលនេះព្ទុយបុរសគប្បីឲ្យឈុងស៊ីសុំទោសគាត់ អ្នកស្រីយល់ថានាយចង់ការពារម្តាយយ៉ាងស្មោះស្ម័គ្រ ។ ក្នុងមួយជីវិតមានកូនប្រុសពីរនាក់គត់ ហើយចំពោះកូនមួយនេះ គាត់បានចំណាយកម្លាំងកាយកម្លាំងចិត្តមិនចិញ្ចឹមថែរក្សាមុនគេ... រហូតពេលនេះទើបបានស្តាប់ឮសំដីកូនសំណប់ការពារម្តាយជាលើកដំបូង ! គាត់សប្បាយរីករាយពេកក្នុងរំភើប ការលំបាកត្រួយបារម្ភមិនពេញ ចាប់ដែលធ្លាប់ជួបប្រទះជាងម្ភៃឆ្នាំមកហើយនោះ យ៉ាងណា កូននេះអស់រលីង ។

ស៊ីឈីងក្រឡេកមើលកិរិយាដែលញញឹមថ្ងាំចិត្តចំកក្តុកកក់ៗ, គាត់ក្តាប់ដៃភរិយាយ៉ាងណែនទឹកក្តុំពោះថា :

- កូនយល់ចិត្តខ្លួនរបស់វាហ្នឹងហើយ. តែរាស្ត្រស្រឡាញ់ម្ដាណាស់ហ្ន៎ !

ចំណែកឥសីលុងស៊ីបែរជាខឹងព្រឺព្រួច ពីពាក្យត្រូវគោះប៉ះប៉ោកអស់មាណព ក៏ស្រែកសួរ:

- ឯងជាអ្នកណា ? សំគាល់តើអ្នកបានជាហ៊ានបន្ទាប់បន្ថោកឲ្យសុំទោសលោកស្រីស៊ុំ ?

វ៉ុនហ្វូសស្ងួយអ៊ាំ ប៉ុប្រុងជាតិឈប់ទឹងពិងមិនប៉ុន្មានឡើងក្ស បែរមកបារម្ភខ្លាចកូនប្រុសឈ្មោះតាស់ខែន គ្នានាំបែកសាមគ្គីវិញ ម្ល៉ោះហើយគាត់ឆ្លើយថា:

- រឿងនេះជាបងលុងស៊ីប្រទូលទេ, ដំណោយឲ្យក្លាស់លាលបន្ទុចទៅបានហើយ មិនបាច់សុំទោសតែម៉ឹងទេ ។ គាត់បែរទៅកែមាណព គោលពាក្យទន់ភ្លន់:

- អស់លោកឥសីស្ទូរកត្រូវ និងក្រុមារណា ! កូនលុតជង្គង់ផ្គិតផ្គងសួរគាត់ភ្លាមទៅ ។

ស៊ីផានហួសស្រឡាញ់កាប់កែមប្តីប្រពន្ធស៊ុយឈីងកាំងតាំងជួបគ្នាលើកដំបូងម៉្លេះ ៗ ពេលនេះ មកប្រទះទឹកមុខស្លូតបូតញញឹមញញែមប្រិយទន់ភ្លន់ក្រលង់ គោរពគេទៅដោយសេចក្ដីស្នេហារបស់ ចំពោះកូនមាណពកាំកើបចិត្តណាស់ ព្រោះមួយជាតិនេះនាយមិនដែលបានតរណា ស្រឡាញ់ផ្ចិតផ្ចង់ ស្មើនឹងកូនបែបនេះទេ ។ ជាពិសេសកិត្តិយ៉ែកតាំងហួសប៉ុន្មានគ្នាឲ្យត្រូវជាកិត្តិ ៖ ណាម អ្នកម្នាក់ពុះកញ្ជ្រោលក្នុងចិត្តចង់ក្ដីកាមបង្គាប់អ្នកស្រីមួយរំពេចនោះព្រោះផុតយ៉ាងណាក៏មិនព្រួត តែរ កុំជាទៀយព្រមលុតជង្គង់សំពះ !

ស៊ីផានមិនបង្អង់យូរ ម្ដាលុតជង្គង់ដល់ដីសំពះលុងស៊ីជាមួយវាចា :

- បើលោកប្រើប្រើខ្ញុំសំពះអស់លោក ខ្ញុំត្រូវតែសំពះ ។

ប្ដីនេះដល់វេនឥសីផានស៊ុនគិនួន ៗ មិនបាំងវិញ ដោយមិនទឹកស្គាល់ មាណពស្ដាប់បង្គាប់ អ្នកស្រីវុនយូដល់ថ្នាក់ឡើង ។ គេគិតថាប្រហែលជាសង្ស័យប្ដីប្រពន្ធស៊ុយឈីងហើយ ព្រោះ ស៊ុយឈីងគ្មានកូនប្រុសឯណាទៀតទេ , ម្នាក់ស្លាប់ ម្នាក់គេចាប់បាត់ ។

ឥសីលុងស៊ីចិត្តខ្លាំងនៅតែរមែន តែគាត់បេះដូងរណោះ ដោយសុភវិនិច្ឆ័យវៃ ៗ កាលបើ ឃើញមាណពគោរពស្ដាប់គំនិតគាត់រលាយអស់ , គាត់លោតចុះពីខ្នងសេះមកលើកមាណពព្រម ទាំងពោលថា:

- មិនបាច់គួរសមពេកទេ !

ស៊ុំផាបមិនលើកឃើញស្ងៀមថា បើលោកប្រើសុំប្រើឲ្យសំពះ ខ្ញុំត្រូវសំពះគ្រប់ជំនាន់ដរាបសម , ម្ល៉ោះ

ហើយនាយមិនព្រមក្រោកភ្លាមទេ ។ ឈុនស៊ីចាប់លើកបាណាពទទួលអារម្មណ៍ថាម្ចុកតឹអ្នកកម្លោះ ជួនធ្ងុកផ្ទួចក្ដិលើកមិនរបើកសោះ ។ ឥសីចង់ក្រេវឹកថា:

– ឯងទុកជាក់លើងជាអ្នកចាស់ទុំ តែឯងបង់អ្នកកាដកម្លាំងធាតុទៅវិញ , ហ៊ឺះ ! មិនអីទេ!

ឥសីនេះឈ្លក្ខន់ទុកចម្រើនកម្លាំងកាយប្រមូលកម្លាំងបាត ចាប់កន្ត្រាក់បាណាពប្អូនទៀតប្រាប់ឲ្យមាយ ជួលផ្លាក្រោយ ។ ចំណែកប្អូនប្រពន្ធស៊ុំឈើឯគ្រាន់តែឃើញកាយវិការទង់ទឹកមុខឥសីគាត់យល់ គំនិតដ៏ប្ឹងថា ឈុនស៊ីចង់ចម្រើនកម្លាំងកំញើញកូនប្រុសហើយ ! ស៊ុំឈើឯធ្វើហ៊ឹះ ! ម៉្លោះហើយមិនគេញចិត្តតែ គាត់យល់ថាបណ្ដោយឲ្យបងប្រុសប្រុងម៉ៅកូនប្អូនក៏មិនទាល់ខុសដែរ, អ្នកស្រីរុនឃុំមិនព្រមទេ, គាត់ស្រែក យាត់ :

– សូមលោកបងបន្ទន់ដៃសិន !

ប៉ុន្តែភ្លាមនោះឮស្ងួរ ! តីរជកាយឥសីឈុនស៊ីខ្ទាតផ្ទាត់ក្រុងលំហកោកាសម៉ុះដើងនោះតាក់យ៉ាងផេណ ពល់តែបញ្ចេញយុទ្ធសិល្បៈទើបទប់ខ្លួនបានទឹងវិញ, ដងនោះគាត់ត្រាកម្លាំងឲ្យលំមិនបានក៏ស្រែកញ្ញាល ជួយទាំងដំហរ ។

ត្បិតស៊ឹផធានមានកម្លាំងធាតុស្ដុកស្ដម្ភហួសការស្មានរបស់ឥសី ដូះជាឈុនស៊ីបាប់លើកនាយ មិនរួច បែរជាខ្ទាតខ្លួនឯងវិញ ។ ហេតុការណ៍នេះប្អូនប្រពន្ធស៊ុំឈើឯនិងឥសីទាំងអស់យល់ច្បាស់ ណាស់ , នរណាក៏ភ្ញាក់ផ្អើលដែរ ។ ស៊ុំឈើឯនឹងវុនឃុំឃ្លាប់ស្គាល់ស្នាដៃបាណាពកូនកេនក្បាស់ គេដឹងថាកម្លោះនេះមានកម្លាំងហួសអាយុ តែមិនស្មានអាចធ្វើឲ្យឈុនស៊ីសិស្សគាស្រមសាំងឈើងខ្ទាត ទៅក្រោយដល់ម្ល៉ឹងទេ ។

ឈុនស៊ីតែកែកម៉ាស់មុខ, ទប់ខ្លួននឹងនវិញហើយហួតផាវិទ្វាក ! ដល់ចឹងពេកទៅគាត់សើចស្ងួត ពោលខ្ទឹកប៉ុតថា:

–ប្រសើរណាស់ !

ឥសីពោលពាក្យ«ប្រសើរណាស់»បីដងទាំងក៏សម្រួលដង្ហើមបានផ្លូវដើមបន្តថា :

–ប្អូនប្រុសប្អូនស្រីបន្ដាត់សិស្សបានល្អពេកចំណាប់មែន ! បងសុំទោសណា !

ពោលផុតពីមាត់រលាស់ចុងដាវចន្ទ្របេះផ្ទូនស៊ីផធានភ្លាម ។ បាណាពយកក្រោយដាប់ប្រញាប់ពាដៃ ញាប់ស្អក:

-ទេ ! ទេ ! ខ្ញុំមិនប្រយុទ្ធជាមួយលោកឡើយ ។

ឥសីធានស៊ីឈរមើលដឹងច្បាស់ថា មាណពរូបនេះមានកម្លាំងខ្ពស់ណាស់, គាត់ពិចារណាថា អ្នកឈុនស៊ីប្រយុទ្ធនឹងវាគឺគ្រូមារវាយសិស្សក្មួយ បើឈ្នះទៅឥតបានប្រយោជន៍អ្វីទេ, លោតែចាញ់វិញឈុនស៊ីយកមុខទៅទុកឯណា ?

ឥសីឃើញស៊ីផធានរាដៃមិនព្រមប្រយុទ្ធត្រូវនឹងបំណងគាត់ម៉ាច់ក៏បញ្ចេញយោបល់ភ្លាម :

-សុទ្ធតែគ្នាឯងទេ, កុំបាច់សាកល្បងគ្នា ។ ទោះចង់ណាស់ក៏មិនត្រូវចង់ពេលនេះដែរ !

ស៊ីផធានងក់ក្បាលយល់ស្រប :

- មែនហើយ , អស់លោកជាបងប្អូនរួមក្រុមបក្សរបស់លោកប្រុសលោកស្រីស៊ុំ , បើខ្ញុំផ្តួលវាយសម្លាប់ខ្លះទៅដូចជាមិនល្អមើល ...

មាណពគ្មានការពិសោធន៍ក្នុងឆាកជីវិត នឹកឃើញយ៉ាងណាពោលវាចាយ៉ាងនោះប៉ះបំពូនចិត្តឥសីឡុងនឹងគ្រោធគ្រប់គ្នា ។ ស៊ីផធានក្រែងរអែង ដោយហេតុដៃខ្លួនមានស្នាមក្រហមខៀវពោរពេញដោយជាតិពិសពិណាប , ឥសីស្មានថាអ្នកម្នោះក្មេងល្ងង់ហ៊ានប្រមាថជីវិតគាត់ ។ ស៊ុណឹងពោលគាត់ :

- ឯងថាម៉េច ? កុំនិយាយផ្តេសផ្តាសទៀត !

ឈុនស៊ីស្តាប់បញ្ជានាយក្រុមថយទៅក្រោយមែន តែក្តីបំផ្លើមាណពភ្លាម គាត់ខឹងឆេះធ្លុះពោះជំហានរឹងគំហក:

- ល្អណាស់ អាល្អិត ! យើងចង់មើលដែរ តើឯងសម្លាប់ពួកយើងដោយវិធីណា ? ចូលមក

ស៊ីផធាននៅតែរាដៃ:

- ទេ ! ទេ ! ខ្ញុំមិនហ៊ានប្រយុទ្ធជាមួយលោកឥសីទេ ។

ឈុនស៊ីរឹតតែក្តៅស្រែកខមង៉ក់ :

- ហ៊ឺះ ! ឯងខ្ពើមរអើមយើងឬ ?

ពោលផងរុញដាវចាក់របងសំដៅស្មា ។ ឥសីរូបនេះមិនឃើញមាណពមានការុណ ទើបសំដៅកន្លែងមិនសំខាន់ ប៉ុន្តែទោះបីមិនពូកែគុនដាវដូចស៊ុណឹង ក៏គាត់មានកាយវិការរហ័សរហួនមិនចាញ់អ្នកណាដែរ ។

Khmer Story Lovers



ស៊ីផានផ្អៀងខ្លួនគេចមិនទាន់ព្នួរឈើប ! ពុនដាវចាក់ត្រូវសាច់ស្មានាយទៅញ៉ាណាខេត្តុល ! អ្នកស្រីរុនយូស្រែកយំ ។ ពុនស៊ីគំហកថែម :

- ហូតដាវចេញមក !

ស៊ីផានចិត្តក្តួនចិត្ត :

- ឯងត្រូវជាបងរួមគ្រូរបស់លោកស្រីស៊ី ។ អប្បាញ់មិញយើងប្រយុទ្ធគ្នាសម្លាប់ឥស៊ីពីរឡូទៅហើយ បើសម្លាប់ឯងម្នាក់ទៀតឃើញថាកក្រក់ណាស់, លោកស្រីស៊ីមិនសប្បាយចិត្តទេ ។ ម្យ៉ាងទៀតយើងមិនចង់ក្លាយខ្លួនទៅជាមនុស្សកក្រក់ពុតរបេខទេ ។

ពេលឥស៊ីរុញបងដាវមកនោះ ម៉ាណាពកបលើកដៃរងកាត់ពុតម្រាមដៃ...ពាក់ធ្លាក់ដៃត្រូវឥស៊ីផ្តួលស្លាប់ទៀត ឃ្លាននាងនាយក្រញាត់ដៃទៅក្រោយក្តាប់...ស្ទុះវាយ...នោះ សុខចិត្តទទួលគ្រោះថ្នាក់យ៉ាងអន់អាច ។ ឥស៊ីតាំងឡាយឃើញ...ប្រែបនេះគេយល់ខុសថានាយប្រមាថសិស្សកស្រុបសាំងពីងតិតព្រោកដ ។ ស៊ូយ៉ូលោកស៊ីពានស៊ីដែលជាចាស់ទុំលើសសិស្សទាំងអស់ក៏ខឹងទាំងដែរ ។ ...ខណៈនោះ...ថ្ងៃនោះ:

- លោកបងឈុងស៊ុ , អាក្មេងនេះព្រហើនគោរពកាចអស្ចារ្យហើយ , ...ដៃបន្តិចទៅ ។

ឥស៊ីឈុងស៊ីស្រែកសន្ទាប់ម៉ាក់ម៉ាណាព :

- ឯងពិតជាមិនព្រមប្រយុទ្ធជាមួយយើងមែនឬ ?

ឥស៊ីមិនចាំម៉ាណាពឆ្លើយរុកដាវចាក់វែប ១ ពីរស្មៀតមួយរំពេច ។ ស៊ីផានមិនស្គាល់ ខ្លួនដាវ ហើយមិនប្រុងខ្លួនតទល់នឹងគេផង ក៏គេចឥតរួត ត្រូវរបួសដៃ...ស្មា ថែមទៀត ។

ដោយហេតុក្រុមឥស៊ីគ្មានបំណងប្រហារជីវិតនាយទើបឈុងស៊ីរុញដាវប៉ះសាច់ ម៉ាណាពបក់ស្បែក បន្តិចក៏ដកចេញវិញភ្លាម ។ អ្នកស្រីរុនយូឃើញកូនសំណប់ចិត្តត្រូវរបួសតាំងពីកើតក្នុងនោះត្រាប យ៉ាងណាក៏ឈឺចាប់ដូចកូនសម្លាញ់ដូចត្រូវរបួសខ្លួនឯងដែរ ។ លុះឃើញពុនស៊ីរុយដាវចាក់ កូនប្រុសថែមទៀតអ្នកស្រីភ័យស្លុតហូតអាវុធខ្លាការពារជំនួសកូនភ្លាម ។ ឮស្នូរដែកដាវប៉ះទង្គិចគ្នាចេញ

ផាន់ផប់ផាន ក្នុងមួយប៉ប្រិចភ្នែក គឺឥសីឈុនស៊ី និងអ្នកស្រីវុនយូ ប្តូរស្នៀតដាវទៅវិញទៅមក បានដប់ប៉ះស្នៀត យ៉ាងរហ័ស ធ្វើឲ្យការៀតរៀងខ្លួនបែកផ្កាភ្លើងព្រាតៗ គួរគយគន់ ។

អ្នកចាំងពីរនៅនឹងត្រូវតែមួយសំផ្លុងគុនដាវខាងអាស្រមសាំងឈីងរហ័សរហួនបែបនេះ គ្រប់ដប់ប៉ះស្នៀតក្តាម ឥសីកល់រូបចុះដៃ ហៅក្រោសនៅបើរបង្គួនរួមក្រុម ដោយស្មោះស្មុគ្រ ៗ ក្នុងចំណោមនេះ, មានតែស៊ីផានម្នាក់ទេ ដែលមិនស្គាល់ជំនាញខាងវិជ្ជាគុនដាវ តែងាយចាំតាមមើលក្បួនដកដង្ហើមដែរ ។

ឥសីផានស៊ីយល់ថា ប្រយុទ្ធតទៅទៀតមិនងាយដឹងចាញ់ឈ្នះ ក៏ស្រែកសួរ :

- ប្អូនស្រីពិតជាចង់ការពារកាក្មេងនេះមែនឬ ?

អ្នកស្រីមិនឆ្លើយងាកទៅសួរយោបល់ស្វាមី ។ ស៊ីឈីញបន្ទឹកថា :

- ក្មេងនេះព្រហើនគោងកាចគ្មានស្គាល់ចាស់ទុំ គួរប្រដៅវាឲ្យរាងចាលម្តងមែន ។ លោកបងឈុនស៊ីចាត់វាបីដាវរបួសគ្រប់គ្រាន់ហើយបែបនេះ បើលោកបងមិនយោគយល់, វាគ្មានគង់ជីវិតដល់ពេលនេះទេ ។ ក្មេងនេះមានតម្រិះវិជ្ជាអន់ខ្សោយណាស់ មិនសមប្រយុទ្ធជាមួយលោកបងឈុនស៊ីទេ ។ នែកូនចាប់លុតជង្គង់សំពះសុំទោសគ្រូគឺទៅ ។

ឈុនស៊ីស្រែកខ្លាំង ១ :

- អាល្អិតនេះប្រមាថអាស្រមសាំងឈីងយើងចាំងមួលណា ! វាមិនប្រយុទ្ធនឹងយើងសោះ, ហាមាត់ឡើងសុទ្ធតែកេសម្លាប់ពួកយើងផង !

ស៊ីផានពិបាកចិត្តណាស់លាបាតដៃចាំងពីរមើលម្តងទៀត ឃើញស្នាមក្រហមនិងខៀវនៅដដែល, ងាយដកដង្ហើមយូរ ពោលម្នាក់ឯង :

- ដៃខ្ញុំមួយគូនេះចង្រៃណាស់, ហាក់ដូចជាដើមហេតុនៃគ្រោះកាចចាំងឡាយ ។ នៅស្ងៀម ១ សោះវាយមនុស្សស្លាប់ទទេ ១....ហ៊ឺ !....

ពពួកឥសីនៅអាស្រមសាំងឈីងថ្ពោះទឹកមុខព្រមគ្នា ។ ស៊ីឈីងពុមាណពេលពាក្យមិនគប្បីបែបនេះគាត់ខឹងដែរស្រែកសន្ធាប់ :

-យី ! អាចង្រៃនេះគ្មានដឹងខុសត្រូវអ្វីសោះ ! អម្បាញ់មិញលោកគ្រូអឹឈុនស៊ីមិនសម្លាប់ព្រោះគាត់យោគយល់ដល់រូបយើងណា ! មើចឯងនៅមិនដឹងខ្លួនទៀត ?

ស៊ីផានឆ្លើយឥតរួចបានតែខ្ញុំ . . . ខ្ញុំ . . .

ផាស៊ីល្បើស៊ីតយ៉ាងពាក់ពីរផ្លូវ ៗ គាត់សង្កេតឃើញកាយវិការដែលទាយគេចចេញមិនសមជាក្មេងរៀនស្បៀតនុងផាវទាងកក្រមសាំងឈើងនោះ, ប៉ុន្តែមានគប្បាំងសង្កត់ចេញមកពីចប៉ុក ៗ គាត់សង្ស័យថាមាណពមិនមែនសិស្សប្អូនប្រពន្ធស៊ុំឈើងទេ ៗ លុះឃើញមាណពពេទ្យធាតដៃមើលគាត់ផុតក្តិនធ្លាបកាយ ១ គឺស្រែកសួរភ្លាម :

– នែកាប្រមក់ឯងជាសិស្សអ្នកណា ម្តេចមាត់រឹងម៉្លេះ ?

ស៊ីផានឆ្លើយ :

– ខ្ញុំ . . . ខ្ញុំជាសិស្សឡូនទាងក្រុមព្រះកាចក្ស ៗ

លុបន៍ស៊ីស្រឡាំងកាំងកេងឹក :

– ក្រុមព្រះកាចក្សព្រះចន្ទណាអីចេះ ? ក្នុងពិភពលោកហាក់ដូចមិនដែលឮ ពួកក្រុមហ្នឹងទេ ៗ កាប្រមក់ចេះកុហកផងហ្ន !

ដោយជឿជាក់ថាមាណពមិនមែនសិស្សប្អូនប្រពន្ធស៊ុំឈើងហើយ ផាស៊ីបង្វែរបាថា :

– យើងស្មានតែឯងជាសិស្សបំណាច់របស់ប្អូនស៊ុំឈើង ឥឡូវនឹងហើយបងមែនគ្នានឹងនោះ ៗ

ពោលចប់ ផាស៊ីបិទស្លឹកផាសញ្ញាប្រាប់ប្អូនរូបត្រូពីររូបឈរក្បែរនោះភ្លាម ៗ ផាស៊ីទាំងពីរយល់ការចេះបង្វិលផ្លែផារបញ្ចេញស្បៀតព្រមគ្នា មួយពាក្យប្រងំស៊ុំឈើង មួយទៀតបង្អុលប្អូនប្រើវុនយូៗ នេះជាស្បៀត „ សំពះទៅលើ „ សម្រាប់សម្តែងគារវកិច្ចទទួលសត្រូវទៅគ្រាដំបូង ឬសម្រាប់ចូលប្រយុទ្ធជាមួយអ្នកបាស់ចុំ ៗ គេកាន់ផាវក្នុងដៃត្រង់ចុងម្ខាងចុងទៅក្រោម ដូចលំនៅកាយគោរពមែន តែគេកាចការពារខ្លួនបានផុំវិញ ក្នុងករណីដែលសត្រូវវាយលុក, បើសត្រូវនៅស្ងៀមគេនៅស្ងៀមដែរ ៗ

ស៊ុំឈើងនិងកិរិយាស្គាល់ស្បៀតនុងផាវនេះច្បាស់ណាស់ ហើយលំច្បាស់ថា បើគាត់នៅតែចេញមុខការពារមាណព ផាស៊ីទាំងពីរផ្តាត់ផ្លែផាវទៅរឹងលើភ្លាម , បើគាត់នៅស្ងៀមគេមិនបញ្ចេញសកម្មកិរិយា ឬ កាយវិការណាមិនគួរគប្បី ឲ្យខូចមិត្តភាព ឬ សាមគ្គីភាពរវាងប្អូនប្រពន្ធគាត់ និងសិស្សកក្រមសាំងឈើងទាំងអស់ទៀយ ៗ

អ្នកស្រីវុនយូសម្លឹងផាស៊ីលំងស៊ីដែលកាន់ផាវឈរបំពោះមុខគាត់ និកថា :

-កាលនៅហាត់រៀនយុទ្ធសិល្បៈក្នុងសម្រមសាំងឈីងជាមួយគ្នា, បងរួមគ្រូនេះលើកដៃលើកជើងសាំងជីងគុនជាវមិនហ៊ានហួសពីយើងទេ ។ ពេលនេះគាត់ល្អកលាស់ច្រើន ជាងមុនឆ្ងាយគ្រាន់បើ, ក្រែងប្រយុទ្ធគ្នាត្រឹមតម្លៃសារបស់ខាងស្មៀតមិនដឹងឈ្នះចាញ់ទេដឹង ?

ក្នុងពេលអ្នកស្រីនឹកពិចារណានោះ, ឥសីឈុនស៊ីលាស់ដាវវែងៗជុំវិញខ្លួនស៊ីផាន ព្រមទាំងស្រែកសន្ធឹ,

- បើឯងមិនព្រមតដៃ, យើងសម្លាប់កាសិស្សកំណាចខាងក្រុមព្រះអាទិត្យឯងចោលភ្លាម ។

ឥសីសង្កត់ពាក្យ « សិស្សក្រុមព្រះអាទិត្យ » ក្នុងគោលបំណងមិនឲ្យស៊ីឈីងចោទប្រកាន់គាត់នៅថ្ងៃក្រោយ ។ ស៊ីឈីងគិតពិចារណារួចហើយថា:

- បើកូនប្រុសយើងមិនតប លោកឈុនស៊ីពិតជាវាយវាប្អូសច្រើនទៀតមិនខាន, ប៉ុន្តែបើកូនយើងតដៃ, យើងហ៊ានទាយថាលោកមិនប្រើដៃធ្ងន់ទេ, ខ្លាំងណាស់ត្រឹមចុចពីតចពចរម្ភ ចាក់ថែមពីរបីកន្លែងឲ្យរបួសស្រាលៗ គ្រាន់គំរាមកំហែងកូនប្រុសនេះ កុំឲ្យក្រអឺតក្រទមពេក

ដោយយល់បែបនេះស៊ីឈីងស្រែកប្រាប់ស៊ីផានភ្លាម :

- នែកូន, លោកគ្រូអ៊ីចង់បង្ហាត់គុនវិជ្ជាខ្លះដល់កូនជាប្រយោជន៍សិក្សាឯងទេតើ ! ចូរកុំខ្លាច, គាត់មិនវាយឯងឲ្យមានរបួសទេ ។ ហូតការុធរងភ្លាមទៅ !

ស៊ីផានគំពុងភ័យប៉ុន្តែដោយពន្លឺដាវឥសីបាំងជុំវិញខ្លួន ។ នាយដឹងថាឥសីឈុនស៊ីមានយុទ្ធសិល្បៈខាងគុនដាវពូកែលើសនាយឆ្ងាយណាស់, គ្រាន់តែឮស៊ីឈីងបើកឲ្យប៉ាប់ភ្លាមនាយស្រែក :

- មែន ! បើយើងប្រើការុធរងកាត់ទន្ទឹងដាវគាត់ ដាវពិតក្នុងបារៈដៃយើងមិនទាន់ប៉ះគាត់ស្លាប់កើតទេ ។

នាយពេលក្មេកក្រឡេកឃើញកាំបិតមួយដេកស្តូកលើដីផលចុះសេសារទៀត សិស្សឈុនស៊ីម៉ាំហោះចោល ហើយស្រែកយ៉ាងប្រញាប់:

-បាទ ! បាទ ! ខ្ញុំតដៃវិញហើយ ។ សូមលោកឥសីកុំកាលចាក់ទំ [illegible] ចាំខ្ញុំរើសកាំបិតនាងណោះមកសិន, លោកអ្ទៀតពេលចាក់ខ្លួនខ្ញុំមិនបានទេណា ! សូមលោកឥសីកុំធ្វើផ្តេសផ្តាស ។

(នៅមានត)

ដំកល់ទុកតាមលេខ ៣៤២ ចុះថ្ងៃទី ៣ ៦ . ៧០ — បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers